ស៊ូប ភ្នំ ណាព្រៃ

# គ្រឹះយើងខ្លួនធនមិនខ្លួនទូន

# ប្រែចង់ឆ្លិខ្ញុំ

# ឧត្តមខ្លិខ្ញុំបំផុត

# ផ្កាមួយគ្រឹះមនុស្សខ្លួនចុះសេរី

# ផ្ទៃមិត្តធនពាក្យសន្យាចុះខ្លួន

# តើសាវកប៉ុលបង្រៀនពួកសាសន៍ ដទៃមិនឲ្យរក្សាថ្ងៃសប្ប័ទ និងថ្ងៃបុណ្យ បរិសុទ្ធរបស់ព្រះឬ?


## ខ្មែរស្ងួនត្វាហៅសំរាប់ព្រះ

Khmer Brethren Called for God

sabbathreflections.org

## ឆ្លុះបញ្ចាំងថ្ងៃសប្ប័ទ

ទំនាក់ទំនង:E-mail:chumbou2020@gmail.com

016 509 779/ 097 990 6244/011 435 441

បទគម្ពីរចម្លងក្នុងខិត្តប័ណ្ណនេះ
ដកស្រង់ចេញពីគម្ពីរបោះពុម្ព ឆ្នាំ១៩៥៤

«កុំឲ្យគិតស្មានថា ខ្ញុំ...[ព្រះយេស៊ូវ]... មកដើម្បីនឹងលើកក្រិត្យវិន័យ ឬ ទំនាយពួកហោរាចោលឡើយ ខ្ញុំមិនមែនមកនឹងលើកចោលទេ គឺមកនឹងធ្វើឲ្យសំរេចវិញ ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា នឹងគ្មានបាំងឈើមួយ ឬក្បៀសមួយនៅក្នុងក្រិត្យវិន័យ ត្រូវបាត់ឡើយ ដរាបដល់កាលណាមេឃ នឹងផែនដី បានកន្លងបាត់ទៅ គឺទាល់តែសេចក្ដីទាំងអស់បានសំរេច ដោយសព្វគ្រប់»
(ម៉ាថាយ៥:១៧-១៨)

**Sabbath Reflections ឆ្លុះបញ្ចាំងថ្ងៃសប្ប័ទ**

ទំនាក់ទំនង: E-mail:chumbou2020@gmail.com
ទូរស័ព្ទលេខ: 016 509 779/ 011 435 441/ 097 990 6244

# អារម្ភកថា

មានអ្នកគ្រីស្ទាន ឬគ្រីស្ទបរិស័ទ (មិនមែនគ្រីស្ទានទេ) ជាច្រើននាក់ បានយល់ច្រឡំថា សាវកប៉ុលបង្រៀនដល់ពួកសាសន៍ដទៃ មិនឲ្យរក្សាថ្ងៃសប្ប័ទ នឹងថ្ងៃបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះ។ ថ្ងៃសប្ប័ទ ឬថ្ងៃឈប់សំរាក បានតាំងឡើង ដោយព្រះអទិករ ជាព្រះដែលបង្កបង្កើត របស់សព្វសារពើ នៅគ្រប់ស្ថានទាំងនោះ។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទ្រង់មានថា «...ថ្ងៃឈប់សំរាក បានតាំងសំរាប់ឲ្យមនុស្ស... [មនុស្សដែលកើតពីស្ត្រីមក]...មិនមែនជាមនុស្សសំរាប់ថ្ងៃឈប់សំរាកទេ ដូច្នេះ កូនមនុស្សជាម្ចាស់នៃថ្ងៃឈប់សំរាកដែរ» (ម៉ាកុស២:២៧-២៨) ព្រះអម្ចាស់ទ្រង់មានបន្ទូលថា «ដូច្នេះត្រូវឲ្យរក្សាថ្ងៃឈប់សំរាកទាំងនោះ ដ្បិតថ្ងៃនោះជាថ្ងៃបរិសុទ្ធរបស់ឯងរាល់គ្នា...» (និក្ខមនំ៣១:១៤) ព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅម៉ូសេថា ឯថ្ងៃបុណ្យទាំងប៉ុន្មាននៃព្រះយេហូវ៉ាដែលឯងរាល់គ្នា ត្រូវប្រកាសប្រាប់ទុកជាថ្ងៃប្រជុំជំនុំបរិសុទ្ធ (ថ្ងៃសប្ប័ទ) ថ្ងៃបុណ្យនៃព្រះយេហូវ៉ាទាំងអស់ ជាថ្ងៃបរិសុទ្ធ ឬថ្ងៃសប្ប័ទ ដែលយើងត្រូវរក្សាឲ្យបានបរិសុទ្ធ។

ដោយ ប៊ូ ឈុំ

«កុំឲ្យគិតស្មានថា ខ្ញុំមកដើម្បីនឹងលើកក្រិត្យវិន័យ ឬទំនាយពួកហោរា ចោលឡើយ ខ្ញុំមិនមែនមកនឹងលើកចោលទេ គឺមកនឹងធ្វើឲ្យសំរេចវិញ ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា នឹងគ្មានបាំងឈើ១ ឬក្បៀស១នៅក្នុងក្រិត្យវិន័យ ត្រូវបាត់ឡើយ ដរាបដល់កាលណាមេឃ នឹងផែនដី បានកន្លងបាត់ទៅ គឺទាល់តែសេចក្ដីទាំងអស់បានសំរេច ដោយសព្វគ្រប់»

(ម៉ាថាយ៥:១៧-១៨)

«បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តរបស់ខ្ញុំចុះ... អ្នកណាដែលមានបញ្ញត្តរបស់ខ្ញុំ ហើយកាន់តាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ ឯអ្នកណាដែលស្រឡាញ់ខ្ញុំ នោះជាទីស្រឡាញ់នៃព្រះវរបិតាខ្ញុំហើយ ខ្ញុំនឹងស្រឡាញ់អ្នកនោះដែរ ក៏នឹងសំដែងខ្លួនឲ្យអ្នកនោះស្គាល់ផង»

(យ៉ូហាន១៤:១៥)

«មើល នៅថ្ងៃនេះ អញបានដាក់សំរេចជីវិត នឹងសេចក្ដីល្អនៅមុខឯង ព្រមទាំងសេចក្ដីស្លាប់នឹងសេចក្ដីអាក្រក់ផង ដោយអញបង្គាប់ដល់ឯងនៅថ្ងៃនេះ ឲ្យស្រឡាញ់ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ដើម្បីនឹងដើរតាមផ្លូវទ្រង់ ហើយនឹងកាន់តាមអស់ទាំងសេចក្ដីបង្គាប់ នឹងច្បាប់ ហើយនឹងបញ្ញត្តទាំងប៉ុន្មានរបស់ទ្រង់ ប្រយោជន៍ឲ្យឯងបានរស់នៅ ហើយចំរើនឡើង ហើយប្រយោជន៍ឲ្យព្រះយេហូវ៉ា ជាព្រះនៃឯង បានប្រទានពរដល់ឯងនៅក្នុងស្រុកដែលនឹងចូលទៅចាប់យកនោះ»

(ចោទិយកថា៣០:១៥-១៦)

# តើសាវកប៉ុលបង្រៀនពួកសាសន៍ដទៃមិនឲ្យរក្សា ថ្ងៃសប្ប័ទ នឹង ថ្ងៃបុណ្យបរិសុទ្ធរបស់ព្រះឬ?

សាវកប៉ុលសរសេរ ៨. «នៅវេលានោះ កាលអ្នករាល់គ្នាមិនទាន់ស្គាល់ព្រះ ត្រូវជាប់បំរើដល់អស់ទាំងរបស់ ដែលមិនមែនជាព្រះពីកំណើតទេ ៩. តែឥឡូវនេះ លុះបានស្គាល់ព្រះហើយ (តែស៊ូថា ព្រះបានស្គាល់អ្នករាល់គ្នាវិញជាជាង) នោះធ្វើដូចម្តេចឲ្យអ្នករាល់គ្នាបានត្រឡប់ទៅឯបឋមសិក្សាខ្សោយ ហើយទាបថោក ដែលអ្នករាល់គ្នាចង់ទៅជាប់បំរើម្តងទៀតនោះ ១០. អ្នករាល់គ្នាជាអ្នកកាន់ ថ្ងៃ ខែ រដូវ នឹងឆ្នាំផ្សេងៗ» (កាឡាទី៤:៨-១០) សាវកប៉ុលបានដាស់តឿនដល់ពួកជំនុំនៅរ៉ូម «ដោយគោរពដល់ព្រះអម្ចាស់ដែរ ក៏អរព្រះគុណដល់ព្រះដូចគ្នា» (រ៉ូម១៤:៦) តើចម្លើយត្រឹមត្រូវ ពីអាចំកំបាំងដ៏ពិបាកយល់នៃបទគម្ពីរទាំងនេះយ៉ាងដូចម្តេច? ពួកគ្រីស្ទានអ័ថូដក់ (Orthodox) គេបដិសេធយ៉ាងដាច់ខាត ថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ នឹងថ្ងៃបុណ្យបរិសុទ្ធ ទាំងប៉ុន្មានរបស់ព្រះអម្ចាស់។ ពួកអ្នកដឹកនាំ នឹង សាសនៈវិទូអ័ថូដក់ គេធ្វេសប្រហែសក្នុងការកាត់ស្រាយ សំបុត្ររបស់សាវកប៉ុល គេកាត់ស្រាយដោយលំអៀង ដើម្បីបំពេញគោលបំណងរបស់ពួកគេ ឲ្យបានរក្សាថ្ងៃអាទិត្យ នឹងថ្វាយបង្គំព្រះក្លែងក្លាយ ជាជាងការស្វែងរកយល់សេចក្តីពិត នៅក្នុងព្រះគម្ពីរបរិសុទ្ធវិញ។ ការកាត់ស្រាយព្រះគម្ពីរបរិសុទ្ធមិនត្រឹមត្រូវទាំងនេះធ្វើដូចជាសាវកប៉ុលបង្រៀនឲ្យពួសាសន៍ដទៃ បោះបង់ចោលថ្ងៃ

សប្ប័ទ នឹងថ្ងៃបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះចេញ។ ពួកសាសនៈវិទូ នៃគ្រីស្ទបរិស័ទ គិតថា គម្ពីរសញ្ញាចាស់ គឺសំរាប់តែពួកសាសន៍យូដា ប៉ុណ្ណោះ តាមគំនិតរបស់អ្នកទាំងអស់នោះ គេបដិសេគម្ពីរសញ្ញាចាស់ ទាំងស្រុង ហេតុដូច្នេះហើយ បានជាមានគ្រីស្ទបរិស័ទ [អ្នកជឿសាសនា គ្រីស្ទ] រាប់លាននាក់គិតថា សាវកប៉ុលសរសេរសំបុត្រព្រមានដល់អស់ អ្នករក្សាថ្ងៃសប្ប័ទ នឹងអស់អ្នកធ្វើបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះ គឺ ជាអ្នក «ក្រៅសាសនា» (កាឡាទី២:៨-១០, រ៉ូម១៤:១) បទគម្ពីរទាំង២ នេះជាគំរូ នៃការកាត់ស្រាយរបស់ពួកសាសនៈវិទូ នៃពួកគ្រីស្ទបរិស័ទ បានបន្ទរបទគម្ពីរ ឲ្យមើលទៅដូចជាសាវកប៉ុល បានបំបាត់ចោល បញ្ញត្តិនឹងថ្ងៃបុណ្យបរិសុទ្ធ ទាំងប៉ុន្មានរបស់ព្រះចោលចេញ។

## តើសាវកប៉ុលបានបង្រៀនដល់សាសន៍ដទៃ យ៉ាងច្បាស់ពីអ្វីខ្លះ?

នេះជាសេចក្ដីបង្រៀនយ៉ាងច្បាស់របស់សាវកប៉ុល ដល់ទៅពួកសាសន៍ យូដា នឹង ពួកសាសន៍ដទៃ ឲ្យរក្សាថ្ងៃសប្ប័ទ ជាក់ស្ដុតាដូច្នេះ មាន សេចក្ដីឈប់សំរាកទុកសំរាប់រាស្ត្ររបស់ព្រះ នៅខាងមុខ» (ហេព្រើរ៤:៩) ម្យ៉ាងទៀត ពេលយើងពិនិត្យពីព័ន្ធកិច្ចដំណឹងល្អរបស់សាវកប៉ុល ដល់ សាសន៍ដទៃ បានឃើញយ៉ាងច្បាស់ថា សាវកប៉ុលបានបង្រៀនដល់ សាសន៍ដទៃ ឲ្យកាន់ខ្ជាប់ខ្ជួន នៅថ្ងៃសប្ប័ទ ឬថ្ងៃឈប់សំរាក ជាថ្ងៃទី៧ មិនមែនថ្ងៃអាទិត្យទេ។ កាលចាប់ផ្ដើមដំណឹងល្អ នៅជើងលើកទី១ សាវកប៉ុល នឹងបាណាបាស បានបង្រៀននឹងបញ្ចុះបញ្ចូលដល់ពួកយូ

ដា នឹងពួកសាសន៍ដទៃ ឲ្យថ្វាយបង្គំព្រះនៅថ្ងៃសប្ប័ទ ឬថ្ងៃទី៧ នៅគ្រប់ទាំងសាលាប្រជុំរបស់សាសន៍យូដា នៅក្រុងអាន់ទីយ៉ូក។ គម្ពីរកិច្ចការ ១៣:៤២-៤៤ បន្ទាប់ពីប៉ុល នឹងបាណាបាស បង្រៀនដំណឹងល្អ នៃព្រះព្រះយេស៊ូវគ្រីស្ទ នៅសាលាប្រជុំសាសន៍យូដាចប់ហើយ ៤២.«...នោះពួកសាសន៍ដទៃ ក៏សូមឲ្យប៉ុលអធិប្បាយតាមសេចក្ដីទាំងនោះ នៅថ្ងៃឈប់សំរាក...[ថ្ងៃសប្ប័ទ]...មួយក្រោយទៀត ៤៣. កាលពួកអ្នកប្រជុំបានបែកចេញពីគ្នាទៅ នោះមានពួកសាសន៍យូដា នឹងពួកចូលសាសន៍ជាច្រើនដែលមកថ្វាបង្គំ គេដើរតាមប៉ុល នឹងបាណាបាស ដែលទូន្មានឲ្យគេកាន់ខ្ជាប់ក្នុងព្រះគុណលនៃព្រះ ៤៤. ដល់ថ្ងៃឈប់សំរាកក្រោយនោះ ពួកអ្នកក្រុងស្ទើរតែទាំងអស់ ក៏មកប្រជុំគ្នា ដើម្បីស្ដាប់ព្រះបន្ទូល» យើងរៀនពីកំណត់ យ៉ាងច្បាស់លាស់ សេចក្ដីបង្រៀនរបស់សាវកប៉ុលពីដំណឹងល្អដល់ពួកសាសន៍ដទៃ។ ១) គោលបំណងរបស់សាវកប៉ុលគឺបង្រៀនពួកសាសន៍ដទៃ ឲ្យរក្សាថ្ងៃឈប់សំរាក ឬថ្ងៃទី៧ ឬថ្ងៃសប្ប័ទ នឹងកាន់តាមបញ្ញត្តិ ជាពិសេសរក្សាថ្ងៃសប្ប័ទ សាវកប៉ុលមិនបានបង្រៀនឲ្យពួកសាសន៍ដទៃបោះបង់ចោលថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ ទៅគោរពថ្វាយបង្គំព្រះថ្ងៃអាទិត្យនោះទេ។ សាវកប៉ុលបានប្រាប់ដល់ពួកសាសន៍ដទៃ ឲ្យជួបជុំគ្នានៅថ្ងៃសប្ប័ទក្រោយទៀត ដើម្បីស្ដាប់លោក នឹងបាណាបាស បង្រៀនព្រះបន្ទូលពិតរបស់ព្រះ ២) សាវកប៉ុលបានប្រាប់ពួកគេ ឲ្យបន្តនៅក្នុងព្រះគុណនៃព្រះដោយកុំឲ្យបោះបង់ចោល បញ្ញត្តិ

ច្បាប់របស់ព្រះអង្គ។ យើងបានអត់ទោសបាប ដោយសារព្រះគុណនៃព្រះ ហើយបានទទួលសេចក្ដីសុចរិត ដោយសារព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងដែលទ្រង់បានអត់ទោសអំពើបាបកន្លងទៅរបស់យើង ដោយយើងបានប្រព្រឹត្តរំលងក្រិត្យវិន័យដ៏បរិសុទ្ធរបស់ទ្រង់ (១យ៉ូហាន៣:៤) អស់អ្នកណាដែលបានអត់ទោសបាបហើយទាំងបានញែកចេញជាបរិសុទ្ធ ហើយអ្នកនោះ មិនត្រូវរស់នៅក្រោមបន្ទុករបស់អំពើបាបទៀតឡើយ (យ៉ូហាន១៥:១៤, យ៉ូហាន៨:១១, រ៉ូម៦:១)

## កុំប្រព្រឹត្តរំលងបញ្ញត្តិ

ចូរប្រែចិត្តជឿព្រះយេស៊ូវគ្រីស្ទ នោះអ្នកនឹងទទួលបានការអត់ទោសអំពើបាប។ សាវកប៉ុលមិនដែលបង្រៀនឲ្យពួកសាសន៍ដទៃ បោះបង់ចោលបញ្ញត្តិរបស់ព្រះនោះទេ។ សាវកប៉ុលសរសេរទៅកាន់ពួកជំនុំរ៉ូមជាពួកជំនុំសាសន៍ដទៃ «ដូច្នេះ តើយើងឈ្មោះថាធ្វើឲ្យក្រិត្យវិន័យទៅជាឥតប្រយោជន៍ ដោយសេចក្ដីជំនឿឬអី? ទេ មិនមែនឡើយ គឺឈ្មោះថាយើងតាំងក្រិត្យវិន័យឲ្យកាន់តែមាំមួនឡើងវិញទេតើ» (រ៉ូម៣:៣១) អ្នកគ្រីស្ទានពិត មានក្រិត្យវិន័យចារឹកទុកនៅក្នុងចិត្ត នឹងកត់ក្នុងគំនិត ហេព្រើរ ១០:១៦ «ឯសេចក្ដីសញ្ញា ដែលអញនឹងតាំងដល់គេក្រោយគ្រានោះ គឺថាអញនឹងដាក់ក្រិត្យវិន័យអញនៅក្នុងចិត្តគេ ហើយនឹងកត់ទុកនៅក្នុងគំនិតគេផង» ហើយសាវកប៉ុលបន្តបង្រៀនដល់ពួកសាសន៍ដទៃ រ៉ូម៦:១ «ដូច្នេះ យើងនឹងថាដូចម្ដេច តើត្រូវឲ្យយើងចេះតែប្រព្រឹត្តអំពើបាបទៅ

ទៀត ដើម្បីឲ្យព្រះគុណបានចំរើនឡើងឬអី? ២២.ទេ មិនត្រូវឡើយ ធ្វើដូចម្តេចឲ្យយើងដែលស្លាប់ខាងឯអំពើបាបហើយ បាននៅរស់ក្នុងអំពើបាបទៀតបាន» (រ៉ូម៦:១-២)

## ឯកសារដើមនៃគម្ពីរកាឡាទី៤:៨-១០

ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលសាវកប៉ុលបង្រៀនដល់ពួកជំនុំកាឡាទី រួមទាំងការកាន់ខ្ជាប់តាមច្បាប់របស់ព្រះអង្គផង។ ពួកជំនុំកាឡាទីប្រឈមមុខនឹងពួកអ្នកបង្រៀនដំណឹងល្អមួយផ្សេងទៀត។ ហេតុនេះហើយ បានជាសាវកប៉ុលសរសេរ កាឡាទី១:៦-១២ ១៦. «ខ្ញុំឆ្ងល់ណាស់ពីដំណើរដែលអ្នករាល់គ្នាបានផ្លាស់ប្រែចេញពីព្រះ...[ព្រះវរបិតា]...ផ្សេងទៀតនោះ ១៧. ដែលមិនមែនជាដំណឹងល្អ១ទៀតទេ គឺមានមនុស្សខ្លះបំភាន់អ្នករាល់គ្នាវិញ ហើយចង់បន្លំដំណឹងល្អព្រះគ្រីស្ទផង ១៨.ប៉ុន្តែបើយើងខ្ញុំ ឬ ទេវតាពីស្ថានសួគ៌ នឹងប្រាប់ដំណឹងណាមកអ្នករាល់គ្នាខុសពីដំណឹងល្អ ដែលយើងខ្ញុំបានប្រាប់ហើយ នោះឲ្យគេត្រូវបណ្តាសាចុះ ១៩. ឯសេចក្តីដែលខ្ញុំទើបនឹងនិយាយអម្បាញ់មិញនេះ នោះខ្ញុំនិយាយម្តងទៀតថា បើអ្នកណាប្រាប់ដំណឹងណា ខុសអំពីដំណឹងល្អដែលអ្នករាល់គ្នាបានទទួលហើយនោះឲ្យគេត្រូវបណ្តាសាចុះ ១១០.ដ្បិតតើខ្ញុំរកបញ្ចុះបញ្ចូលអ្នកណា តើជាមនុស្ស ឬព្រះ ឬចង់បំពេញចិត្តមនុស្សឬអី បើសិនជាខ្ញុំចង់បំពេញចិត្តមនុស្ស នោះខ្ញុំមិនមែនជាបាវបំរើរបស់ព្រះគ្រីស្ទទេ ១១១. បងប្អូនអើយ ខ្ញុំចង់ប្រាប់ឲ្យអ្នករាល់គ្នាដឹង

ច្បាស់ថា ដំណឹងល្អដែលខ្ញុំបានថ្លែងប្រាប់ នោះមិនមែនតាមមនុស្សទេ ១២. ដ្បិតខ្ញុំមិនបានទទួលមកពីមនុស្ស ក៏គ្មានអ្នកណាបង្រៀនខ្ញុំផង គឺដោយព្រះយេស៊ូវគ្រីស្ទបានបើកសំដែងវិញ» (១៦-១២) គម្ពីរកាឡាទី ជាគម្ពីរមួយនៅក្នុងគម្ពីរសញ្ញាថ្មី ដែលមានការបកប្រែមិនត្រឹមត្រូវតាមឯកសារដើមជាច្រើនកន្លែងៗ នៅពួកជំនុំកាឡាទី មានបញ្ហា៤យ៉ាង: ចំណែក បញ្ហាទី២ នឹងទី៣ អាចដោះស្រាយយ៉ាងសង្ខេបបាន:

**បញ្ហាទី១: ការកាត់ស្បែក**

ពួកសាសន៍យូដា បានដាក់បន្ទុកលើសាសន៍ដទៃ ឲ្យកាត់ស្បែក (កាត់ស្បែកចុងស្វាស) ទើបអាចត្រឡប់ជាគ្រីស្ទាន នឹងចូលទៅក្នុងសាលាប្រជុំរបស់ពួកគេបាន។ ព្រះយេស៊ូវគ្រីស្ទទ្រង់មានបន្ទូលថា ២៥. «រីឯការកាត់ស្បែក នោះមានប្រយោជន៍មែន បើអ្នកប្រព្រឹត្តតាមក្រិត្យវិន័យ តែបើអ្នកប្រព្រឹត្តរំលងក្រិត្យវិន័យវិញ នោះការដែលទទួលកាត់ស្បែក បានត្រឡប់ដូចជាមិនកាត់វិញ ២៦. ដូច្នេះ បើសិនជាពួកដែលមិនកាត់ស្បែក គេកាន់តាមបញ្ញត្តិក្រិត្យវិន័យទៅ នោះការដែលមិនបានកាត់ស្បែក តើមិនរាប់ដូចជាបានកាត់វិញទេឬអី ២៧. ហើយពួកអ្នកដែលមិនបានកាត់ស្បែកតាមបវេណីយ បើគេប្រព្រឹត្តតាមក្រិត្យវិន័យសព្វគ្រប់ តើគេមិនជំនុំជំរះអ្នកទេឬអី ដែលអ្នកមានទាំងគម្ពីរ នឹងការកាត់ស្បែកផង តែចេះតែប្រព្រឹត្តរំលងក្រិត្រវិន័យវិញ ២៨. ឯដំណើរដែលហៅថាសាសន៍យូដា នោះមិនមែនចំពោះតែអ្នកណា ដែលមានទីសំគាល់ខាងក្រៅ

ប៉ុណ្ណោះទេ ហើយការកាត់ស្បែកសោត ក៏មិនមែនចំពោះតែកាត់ខាងក្រៅប៉ុណ្ណោះដែរ ២៩. រីឯសាសន៍យូដាដ៏ពិតប្រាកដនោះ គឺខាងក្នុងវិញ ហើយកាត់ស្បែកក៏នៅក្នុងចិត្តខាងព្រលឹងវិញ្ញាណដែរ មិនមែនតាមតែន័យពាក្យប៉ុណ្ណោះទេ មនុស្សយ៉ាងនោះតែងមានសេចក្តីសរសើរ មិនមែនមកពីមនុស្ស គឺពីព្រះវិញ» (២៦-២៩)

**បញ្ហាទី២: ប្រពៃណីយ នឹងទំនៀមទំលាប់របស់សាសន៍យូដា**

សាវកប៉ុល បានបន្ទោសសាវកពេត្រុស នឹងបាណាបាស នឹងអស់អ្នកមកពីក្រុងយេរូសាឡឹមនៅចំពោះមុខ កាឡាទី២ ១១. «ប៉ុន្តែ កាលលោកពេត្រុសបានមកដល់អាន់ទីយ៉ូក នោះខ្ញុំ...[ប៉ុល]... បានទាស់ទទឹងនឹងលោកនៅប្រទល់មុខ ពីព្រោះលោកគួរឲ្យបន្ទោសបាន ១២. ដ្បិតមុនដែលមានអ្នកខ្លះមកពីលោកយ៉ាកុប នោះលោកបានបរិភោគជាមួយនឹងពួកសាសន៍ដទៃ តែលុះគេមកដល់ហើយ នោះលោកដកខ្លួនចេញដោយខ្លាចពួកអ្នកកាត់ស្បែក ១៣. ឯពួកសាសន៍យូដាឯទៀត ក៏ធ្វើជាពើជាមួយនឹងលោកដែរ ដល់ម្លេះបានជាបាណាបាស ត្រូវបណ្តោយតាមអំពើកំពុតរបស់គេទៀត ១៤. កាលខ្ញុំឃើញថា គេមិនដើរត្រង់តាមសេចក្តីពិតនៃដំណឹងល្អទេ នោះខ្ញុំក៏សួរលោកពេត្រុស នៅមុខមនុស្សទាំងអស់ថា បើលោក ដែលជាសាសន៍យូដា មិនប្រព្រឹត្តតាមទំនៀមទំលាប់របស់សាសន៍យូដាទេ គឺប្រព្រឹត្តតាមទំនៀមទំលាប់សាសន៍ដទៃវិញ នោះហេតុអ្វីបានជាបង្ខំឲ្យសាសន៍ដទៃ ប្រព្រឹត្តដូចជាសាសន៍

យូដា ដូច្នេះ ១៥. ឯយើងដែលជាសាសន៍យូដាពីកំណើត ហើយមិនមែនជាអ្នកដែលមានបាបក្នុងសាសន៍ដទៃ» (២១១-១៥) តាមទំនៀមទំលាប់របស់សាសន៍យូដា ហាមឃាត់មិនឲ្យបរិភោគអាហារ ជាមួយសាសន៍ដទៃទេ។ ការដាក់ឲ្យនៅឃ្លាតពីគ្នាមិនមែនជាសំណួរសំរាប់ពួកអ្នកកាន់តាមច្បាប់ នឹងបញ្ញត្តិរបស់ព្រះទេ ពីព្រោះបទគម្ពីរសញ្ញាចាស់មិនដែលបានបង្គាប់ពីការដាក់ឲ្យឃ្លាតពីគ្នា រវាងពួកសាសន៍យូដា នឹងសាសន៍ដទៃនោះឡើយ។

**បញ្ហាទី៣: គឺក្រិត្យវិន័យ នឹងសេចក្តីជំនឿ**

លោកសាវកប៉ុលបានសរសេរពន្យល់ នឹងធ្វើការប្រៀបធៀប អ្នកជឿទៅនឹងសេចក្តីជំនឿ នឹងសេចក្តីសន្យា ដែលព្រះអម្ចាស់បានសន្យានឹងលោកអ័ប្រាហាំ។ កាឡាទី៣ ៦. «ដូចជាលោកបានជឿដល់ព្រះ ហើយសេចក្តីនោះ បានរាប់ជាសេចក្តីសុចរិតដល់លោក ៧. ដូច្នេះ ចូរដឹងថា ពួកអ្នកដែលមានសេចក្តីជំនឿ នោះជាពូជលោកអ័ប្រាហាំហើយ ៨. ហើយដោយគម្ពីរបានដឹងជាមុនថា ព្រះទ្រង់នឹងរាប់ពួកសាសន៍ដទៃជាសុចរិត ដោយសេចក្តីជំនឿ បានជាមានសេចក្តីប្រកាសប្រាប់មក ដល់លោកអ័ប្រាហាំជាមុនថា «អស់ទាំងសាសន៍នឹងបានពរដោយសារឯង» ៩. ដូច្នេះ អស់អ្នកដែលមានសេចក្តីជំនឿនោះឈ្មោះថាបានពរជាមួយនឹងលោកអ័ប្រាហាំ ដែលជាអ្នកជឿដែរ ... ដ្បិតមានសេចក្តីចែងទុកមកថា «ត្រូវបណ្តាសា អស់អ្នកណាដែលមិនកាន់ខ្ជាប់តាមគ្រប់ទាំងសេចក្តី ដែលកត់ទុកក្នុងគម្ពីរក្រិត្យ

*វិន័យ ដើម្បីនឹងប្រព្រឹត្តតាម» (១៦-១០) អ្នកជឿ ដែលប្រែចិត្តពីអំពើបាបបានរាប់ជាសុចរិត នៅក្នុងព្រះគុណនៃព្រះ ដោយប្រព្រឹត្តកាន់ខ្ជាប់ខ្ជួនតាមក្រិត្យវិន័យ។*

## ឯកសារដើមនៃកាឡាទី៤:៨-១០

*ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលលោកសាវកប៉ុលបង្រៀនដល់ពួកជំនុំកាឡាទី រួមទាំងការកាន់ខ្ជាប់តាមបញ្ញត្តិ នឹងច្បាប់របស់ព្រះអម្ចាស់ផង។ ពួកជំនុំកាឡាទីប្រឈមមុខនឹងពួកគ្រូបង្រៀនដំណឹងល្អផ្សេងទៀត ហេតុដូច្នេះហើយ បានជាសាវកប៉ុលសរសេរថាកាឡាទី១ ១៦. «ខ្ញុំ...[សាវកប៉ុល]...ឆ្ងល់ណាស់ ពីដំណើរដែលអ្នករាល់គ្នាបានផ្លាស់ប្រែចេញពីព្រះ...[ព្រះវរបិតា]... ដែលទ្រង់ហៅអ្នករាល់គ្នា ក្នុងព្រះគុណនៃព្រះគ្រីស្ទ ជាឆាប់ម្ល៉េះ នឹងទៅតាមដំណឹងល្អផ្សេងទៀតនោះ» (១៦) គម្ពីរកាឡាទី ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលមានការបកប្រែមិនត្រឹមត្រូវតាមឯកសារដើមជាច្រើនកន្លែង។ ពួកគ្រីស្ទាននិកាយប្រូតេស្តង់មិនយល់ កាឡាទី៣:១៣ នេះទេ! ១១៣. «ព្រះគ្រីស្ទទ្រង់បានលោះយើងរាល់គ្នា ឲ្យរួចពីបណ្តាសារបស់ក្រិត្យវិន័យ ដោយទ្រង់ត្រូវបណ្តាសាជំនួសយើងរាល់គ្នា...[ព្រះគ្រីស្ទលោះយើងឲ្យរួចពីអំពើបាប]...ដ្បិតមានសេចក្តីចែងទុកមកថា ត្រូវបណ្តាសាហើយ អ្នកណាដែលត្រូវព្យួរនៅលើឈើ» ពួកប្រូតេស្តង់គេមិនយល់ ១១៣នេះទេ «...ព្រះគ្រីស្ទទ្រង់បានលោះយើងរាល់គ្នា ឲ្យរួចពីសេចក្តី*

បណ្ដាសារបស់ក្រិត្យវិន័យ...អស់អ្នកណាដែលរំលង ក្រិត្យវិន័យ នោះត្រូវបណ្ដាសា....» ចូរយើងពិចារណា បន្តិចសិន តើក្រិត្យវិន័យជាបណ្ដាសាឬ? សូមយើងមើលគម្ពីររ៉ូម៧:៧-១៤ ៧. «ដូច្នេះយើងនឹងថាដូចម្ដេច តើក្រិត្យវិន័យជាតួបាបឬអី ទេ មិនមែនឡើយ ខ្ញុំមិនបានទាំងស្គាល់បាបផង លើកតែដោយសារក្រិត្យវិន័យចេញ ដ្បិតបើសិនជាក្រិត្យវិន័យមិនបានថា ...«កុំលោភ»... នោះខ្ញុំឥតបានដឹងថា មានសេចក្ដីលោភផងឡើយ ៨. តែកាលអំពើបាបបានឱកាស ដោយសារបញ្ញត្តិ នោះក៏បង្កើតគ្រប់ទាំងសេចក្ដីលោភ នៅក្នុងខ្លួនខ្ញុំវិញ ដ្បិតក្រៅពីក្រិត្យវិន័យអំពើបាបបានស្លាប់សូន្យ ៩. តែពីដើម ក្រៅពីក្រិត្យវិន័យ នោះខ្ញុំបានរស់នៅលុះសេចក្ដីបញ្ញត្តិបានកើតមក នោះបាបក៏រស់ឡើង ឯខ្ញុំក៏ត្រូវស្លាប់វិញ ១០. ហើយខ្ញុំឃើញថា បញ្ញត្តិនោះដែលសំរាប់ឲ្យមានជីវិត នោះបានឲ្យខ្ញុំត្រូវស្លាប់វិញ ១១. ដ្បិតដែលបាបបានឱកាស ដោយសារសេចក្ដីបញ្ញត្តិនោះ ក៏មកបញ្ឆោតខ្ញុំ ព្រមទាំងសំឡាប់ខ្ញុំផង ដោយសារបញ្ញត្តិនោះឯង ១២. ដូច្នេះ ក្រិត្យវិន័យជាបរិសុទ្ធ ហើយសេចក្ដីបញ្ញត្តិក៏បរិសុទ្ធសុចរិត ល្អដែរ ១៣. ចុះសេចក្ដីល្អនេះ បានប្រែទៅជាឲ្យខ្ញុំស្លាប់ឬអី ទេ មិនមែនឡើយ គឺជាបាបវិញទេតើ ដែលនាំឲ្យខ្ញុំស្លាប់ ដោយសារសេចក្ដីល្អនោះ ដើម្បីឲ្យបាបបានសំដែងចេញមកថាជាបាបមែន ហើយឲ្យបាបបានត្រឡប់ជាធ្ងន់ក្រៃលែងដោយសារសេចក្ដីបញ្ញត្តិនោះឯង ១៤. ដ្បិតយើងដឹងថា ក្រិត្យវិន័យត្រូវខាងវិញ្ញាណ តែខ្ញុំនៅខាងសាច់ឈាមវិញ

ដោយបានត្រូវលក់ទៅក្នុងអំណាចរបស់បាប» (១៦-១៤) ក្រិត្យវិន័យ នឹងច្បាប់របស់ព្រះ មិនមែនជាបណ្តាសាទេ អស់អ្នកដែលស្តាប់បង្គាប់ ហើយប្រព្រឹត្តតាមក្រិត្យវិន័យរបស់ព្រះ គឺជាអ្នកដែលមានពរ (ចោទិយកថា ២៨:១-១៤, លេវីវិន័យ២៦:១-១៣) អំពើបាបគឺជាបណ្តាសា។ អំពើបាបគឺជាការប្រព្រឹត្តរំលងក្រិត្យវិន័យ (១យ៉ូហាន៣:៤) ការប្រព្រឹត្តរំលងក្រិត្យវិន័យ គឺត្រូវបណ្តាសា (ចោទិយកថា២៨:១៥-៦៨, លេវីវិន័យ២៦:១៤-៤៦) ដូច្នេះ ក្រិត្យវិន័យជាបរិសុទ្ធ សេចក្តីបញ្ញត្តិក៏បរិសុទ្ធ សុចរិត ល្អ ដែលព្រះអម្ចាស់ទ្រង់បានប្រទានមកយើង។ ពួកមេសាសនា របស់គ្រីស្ទានគ្រប់និកាយ គេបង្កើតព្រះគុណទទឹងច្បាប់ ដោយបោះបង់ចោលព្រះគុណរបស់ព្រះ ហើយផ្សាយដំណឹងល្អមិនពិត។ លោកយូដាសជាប្អូនរបស់ព្រះអម្ចាស់ លោកបានសរសេរថា «ដ្បិតមានមនុស្សខ្លះបានលួចចូល គឺជាពួកអ្នកដែលមានទោសកត់ទុក តាំងពីដើមមក ជាមនុស្សទមិលល្មើស ដែលបំផ្លាស់ព្រះគុណរបស់ព្រះនៃយើងរាល់គ្នា ឲ្យទៅជាសេចក្តីអាសអាភាស ហើយមិនព្រមទទួលព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង ដែលទ្រង់ជាម្ចាស់តែ១ផងទេ» (យូដាស១:៤) ពួកជំនុំកាឡាទី ជាពួកជំនុំសាសន៍ដទៃ ដើម្បីឲ្យយើងយល់បានត្រឹមត្រូវពីអត្ថន័យនៃគម្ពីរកាឡាទី៤:៨-១០ យើងត្រូវយល់ថា កាលពីមុនពួកជំនុំកាឡាទី បានជឿព្រះក្លែងក្លាយជាច្រើន ពួកគេធ្លាប់បំរើព្រះរបស់សាសន៍ក្រេក នឹងព្រះស្រីរបស់សាសន៍អាស៊ី។ ពួកជំនុំកាឡាទី មិន

មែនជាសាសន៍យូដា ហើយក៏មិនដែលប្រព្រឹត្តតាមប្រពៃណីយរបស់សាសន៍យូដា ឬ ប្រព្រឹត្តតាមព្រះគម្ពីរ សញ្ញាចាស់ដែរ។ កាឡាទីជំពូក ២ យើងត្រូវពិចារណាមើល ពីសេចក្តីបង្រៀនរបស់សាវកប៉ុល ដែលលោកបានសរសេរទៅពួកជំនុំទាំង១២ ឲ្យគេកាន់ខ្ជាប់ពួកតាមព្រះបន្ទូលរបស់ព្រះ។សាវកប៉ុលបានបង្រៀនដល់ពួកជំនុំសាសន៍ដទៃទាំងប៉ុន្មាន ដែលប្រែចិត្តជឿព្រះយេស៊ូវគ្រីស្ទ ឲ្យកាន់ខ្ជាប់ខ្លួនថ្ងៃឈប់សំរាក ជាថ្ងៃទី៧ (បច្ចុប្បន្ននេះហៅថាថ្ងៃសៅរ៍) ១កូរិនថូស៧:១៧ «តែត្រូវឲ្យគ្រប់គ្នាដើរតាមដែលព្រះអម្ចាស់បានចែកឲ្យ ហើយតាមដែលព្រះបានហៅមករៀងខ្លួន ខ្ញុំក៏តាំងរបៀបយ៉ាងដូច្នេះ ក្នុងគ្រប់ទាំងពួកជំនុំដែរ» កំណត់ចំណាំ: អំពីសំបុត្ររបស់សាវកប៉ុល ផ្ញើទៅពួកជំនុំកូរិនថូស ដោយបង្រៀនឲ្យពួកជំនុំកូរិនថូស រក្សាថ្ងៃឈប់សំរាក ជាថ្ងៃទី៧ ជាថ្ងៃបរិសុទ្ធរបស់ព្រះអម្ចាស់ ឲ្យប្រារព្ធធ្វើបុណ្យរំលង នឹងបុណ្យនំបុ័ងឥតដំបែជាដើម។ ១កូរិនថូស៥:៦-៨ ៦. «សេចក្តីអំនួតរបស់អ្នករាល់គ្នាមិនល្អទេ តើមិនដឹងថា ដំបែតែបន្តិចអាចនឹងធ្វើឲ្យម្សៅទាំងអស់ដោរឡើងបានទេឬអី ៧. ចូរសំអាតដំបែចាស់ចេញ ដើម្បីឲ្យអ្នករាល់គ្នាបានត្រឡប់ជាដុំម្សៅថ្មីវិញ ដ្បិតអ្នករាល់គ្នាបានឥតដំបែហើយ ព្រោះព្រះគ្រីស្ទដ៏ជាយញ្ញបូជានៃបុណ្យរំលង នោះបានត្រូវថ្វាយជំនួសយើងរាល់គ្នាហើយ ៨. បានជាត្រូវឲ្យយើងធ្វើបុណ្យនេះ ដោយឥតមានដំបែ គឺដោយសេចក្តីស្មោះត្រង់ នឹងសេចក្តីពិតវិញ មិនមែនដោយ

ដំបែចាស់ ឬ នឹងដំបែជាសេចក្តីអាក្រក់ នឹងសេចក្តីកំណាចនោះទៀតឡើយ» (៦-៨) ពួកជំនុំកូរិនថូសភាគច្រើនជាសាសន៍ដទៃ។ សាវកប៉ុលបានបញ្ជាក់យ៉ាងច្បាស់ថា «ដ្បិតព្រះទ្រង់មិនមែនជាព្រះនៃសេចក្តីវឹកវរទេ គឺជាព្រះនៃសេចក្តីសុខសាន្តវិញ ដូចក្នុងអស់ពួកជំនុំបរិសុទ្ធដែរ» (១កូរិនថូស១៤:៣៣)។ ពួកគ្រូគង្វាលក្លែងក្លាយ នឹងពួកខុសឆ្គង គេបង្រៀនថា សាវកប៉ុលបង្រៀនមិនឲ្យពួកជំនុំកាឡាទី កាន់តាមបញ្ញត្តិរក្សាថ្ងៃឈប់សំរាក ឬ ថ្ងៃសប្ប័ទ នឹងមិនឲ្យប្រារព្ធធ្វើបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះ។ សាវកប៉ុលមិនដែលបង្រៀនឲ្យពួកជំនុំសាសន៍ដទៃបោះបង់ចោលថ្ងៃឈប់សំរាក ឬ ថ្ងៃសប្ប័ទ នឹងបោះបង់ចោលថ្ងៃបុណ្យបរិសុទ្ធទាំងប៉ុន្មាន របស់ព្រះអម្ចាស់នោះទេ។ សាវកប៉ុលបង្រៀនគ្រប់ទាំងពួកជំនុំសាសន៍ដទៃ ទាំងប៉ុន្មាន ឲ្យដើរតាមផ្លូវរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយសាវកប៉ុល មិនដែលសរសេរ ឬ បង្រៀនឲ្យពួកជំនុំសាសន៍ដទៃ កាន់ថ្ងៃអាទិត្យ នឹងធ្វើបុណ្យរបស់លោកីយនេះ ជាបុណ្យរបស់ព្រះគ្រីស្ទក្លែងក្លាយ គឺបុណ្យគ្រីស្មាស ឬ បុណ្យណូអែល បុណ្យចូលឆ្នាំ ទិវានៃសេចក្តីស្រឡាញ់ នឹងបុណ្យផ្សេងៗ ដែលបទព្រះគម្ពីរមិនបានបង្គាប់ឲ្យធ្វើនោះទេ។ ពួកសាសនៈវិទូ នៃគ្រីស្តបរិស័ទរបស់លោកីយនេះ មិនបាននឹកចាំថា ពួកជំនុំកាឡាទី ជាពួកជំនុំសាសន៍ដទៃ ដែលបានប្រែចិត្តពីអំពើបាបជឿព្រះយេស៊ូវគ្រីស្ទ ហើយគេបានបោះបង់ចោលទំនៀមទំលាប់ នៃ

ការថ្វាយបង្គំព្រះក្លែងក្លាយ នឹងធ្វើបុណ្យរបស់ព្រះក្លែងក្លាយទាំងអស់នោះចេញ ព្រមទាំងការកាន់អស់ទាំងថ្ងៃ ខែ រដូវ ពេលវេលា នឹងឆ្នាំរបស់ព្រះទាំងអស់នោះផង។ ដូច្នេះហើយ ពួកជំនុំកាឡាទីបានប្រែចិត្តពីអំពើបាប ហើយបំភ្លេចអស់ទាំងព្រះក្លែងក្លាយ នឹងការគោរពដល់ព្រះទាំងអស់នោះចេញ។ លោកលូកាបានសរសេរពីសាវកប៉ុលថា កិច្ចការ២៤:១៤ «ប៉ុន្តែ សូមជំរាបលោកម្ចាស់តាមត្រង់ថា ខ្ញុំ...[ប៉ុល]... ប្រុបាទគោរពប្រតិបត្តិដល់ព្រះនៃពួកឰយុកោយើងខ្ញុំ...» កាឡាទី៤:៨-១០ យើងទាំងអស់គ្នា យល់យ៉ាងច្បាស់អំពីសំបុត្ររបស់សាវកប៉ុល ដែលលោកសរសេរទៅកាន់ពួកជំនុំសាសន៍ដទៃគ្រប់ពួកជំនុំ។ សាវកប៉ុល មិនដែលថ្កោលទោសដល់ពួកជំនុំទាំងអស់នោះទេ រួមទាំងពួកជំនុំកាឡាទីផង ពីការរក្សាថ្ងៃសប្ប័ទ នឹងប្រារព្ធធ្វើបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះ។ មិនមែនដូចពួកសាសនៈវិទូរបស់គ្រីស្តបរិស័ទ នឹងពួកអ្នកថ្វាយបង្គំព្រះថ្ងៃអាទិត្យ ចោទប្រកាន់សាវកប៉ុល ដោយស្មាននោះទេ។ បន្ទាប់ពីប្រែចិត្ត ពីអំពើបាប ពួកជំនុំកាឡាទី បានត្រូវនាំដោយវិញ្ញាណបរិសុទ្ធរបស់ព្រះ ឲ្យបានថ្វាយបង្គំព្រះនៅថ្ងៃបរិសុទ្ធ ឬ ថ្ងៃសប្ប័ទ នឹងប្រារព្ធធ្វើបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះផង។ សាវកប៉ុលបានសរសេរទៅ កាឡាទី៤:៦-៧ ៦. «ដោយព្រោះអ្នករាល់គ្នាជាកូន បានជាទ្រង់ចាត់វិញ្ញាណបរិសុទ្ធនៃព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងចិត្តអ្នករាល់គ្នា ឲ្យបន្លឺឡើងថា អ័ប្បា ព្រះវរបិតាអើយ ៧. ដូច្នេះ អ្នករាល់គ្នាមិនមែន

ជាបាវបំរើទៀតទេ គឺជាកូនវិញ ហើយបើជាកូន នោះនឹងបានមរដកនៃព្រះ ដោយសារព្រះគ្រីស្ទ» (៤៦-៧) សាវកប៉ុលក៏បន្តរំលឹកដល់ពួកជំនុំកាឡាទី ពីព្រះក្លែងក្លាយដែលពួកគេធ្លាប់មានពីមុនមក ៤៨. នៅវេលានោះ កាលអ្នករាល់គ្នាមិនទាន់ស្គាល់ព្រះ...[មិនស្គាល់ព្រះដែលបង្កើតថ្ងៃសប្ប័ទ នឹងថ្ងៃបុណ្យបរិសុទ្ធ]... នោះត្រូវជាប់បំរើដល់អស់ទាំងរបស់ដែលមិនមែនជាព្រះពីកំណើតទេ... [បំរើព្រះក្លែងក្លាយ នឹងអារក្សសាតាំង]... សាវកប៉ុលបានដាស់តឿនពួកជំនុំកាឡាទី យ៉ាងមឺងម៉ាត់ ពីការថ្វាយបង្គំព្រះក្លែងក្លាយ ជាគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរខាងឯវិញ្ញាណ ពីព្រោះគេមិនបានស្តាប់បង្គាប់តាមព្រះ ដោយពួកគេបានត្រឡប់ទៅឯព្រះក្លែងក្លាយ ទាំងបង្កើតឲ្យមានការច្របូកច្របល់នៅក្នុងពួកជំនុំ។ សាវកប៉ុលបានបន្ទោសពួកគេយ៉ាងខ្លាំង ៤៩. «តែឥឡូវនេះ លុះបានស្គាល់ព្រះហើយ (តែស៊ូថា ព្រះបានស្គាល់អ្នករាល់គ្នាវិញ ជាជាង) នោះធ្វើដូចម្តេចឲ្យអ្នករាល់គ្នាបានត្រឡប់ទៅឯបឋមសិក្សាខ្សោយ ហើយទោបថោក...[ដោយឲ្យវិញ្ញាណបិសាចរបស់សាសនាក្លែងក្លាយនាំ]...ដែលអ្នករាល់គ្នាចង់ទៅជាប់បំរើម្តងទៀតនោះ... [បំរើអារក្សសាតាំង ដូចពីមុនទៀត]...៤១០. អ្នករាល់គ្នាជាអ្នកកាន់ថ្ងៃ ខែ រដូវ នឹងឆ្នាំផ្សេងៗ... [ថ្ងៃ ខែ ឆ្នាំ របស់ពួកព្រះក្លែងក្លាយ]...៤១១. ខ្ញុំខ្លាចក្រែងខ្ញុំបានធ្វើការនឿយហត់ក្នុងពួកអ្នករាល់គ្នា ជាឥតប្រយោជន៍» (៤៩-១១) កាលពីមុនពួកកាឡាទីមិនបានស្គាល់ព្រះពិតទេ គេថ្វាយបង្គំអស់ទាំងព្រះផ្សេងៗ ថ្ងៃ ខែ

រដូវ នឹងឆ្នាំ ដែលពួកកាឡាទីធ្លាប់បានកាន់ពីមុននោះ ជារបស់ព្រះក្លែងក្លាយ មិនអាចជួយឲ្យពួកកាឡាទី អាចប្រែចិត្តពីអំពើបាបបានទេ។ ពួកជំនុំកាឡាទីអាចនឹងស្គាល់ព្រះពិតបាន បើសិនជាគេរក្សាថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ ពីព្រោះថ្ងៃសប្ប័ទ ឬ ថ្ងៃឈប់សំរាក ជាទីសំគាល់រវាងព្រះពិត នឹងរាស្ត្ររបស់ទ្រង់ គម្ពីរនិក្ខមនំ៣១ ខ១២. «ព្រះយេហូវ៉ាទ្រង់ក៏បង្គាប់ម៉ូសេ ខ១៣. ឲ្យប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា ត្រូវឲ្យឯងរាល់គ្នាកាន់អស់ទាំងថ្ងៃឈប់សំរាករបស់អញជាកុំខាន ដ្បិតនោះជាទីសំគាល់ដល់អញ ហើយនឹងឯងរាល់គ្នា នៅអស់ទាំងដំណតទៅ ដើម្បីឲ្យបានដឹងថា អញនេះជាព្រះយេហូវ៉ាដែលញែកឯងរាល់គ្នាចេញជាបរិសុទ្ធ ខ១៤. ដូច្នេះ ត្រូវឲ្យរក្សាថ្ងៃឈប់សំរាកទាំងនោះ ដ្បិតថ្ងៃនោះជាថ្ងៃបរិសុទ្ធដល់ឯងរាល់គ្នា អស់អ្នកណាដែលប្រព្រឹត្តកន្ទង់ចំពោះថ្ងៃនោះ នឹងត្រូវសំឡាប់ជាមិនខាន ឯអ្នកណាដែលធ្វើការអ្វីនៅថ្ងៃនោះ នឹងត្រូវកាត់កាល់ពីសាសន៍របស់ខ្លួនចេញ ខ១៥. ក្នុងរវាង៦ថ្ងៃនោះត្រូវធ្វើការបាន តែឯថ្ងៃទី៧ នោះជាថ្ងៃឈប់សំរាកវិញ គឺជាថ្ងៃបរិសុទ្ធដល់ព្រះយេហូវ៉ា ឯអស់អ្នកណាដែលធ្វើការអ្វីនៅថ្ងៃឈប់សំរាកនោះនឹងត្រូវសំឡាប់ចោលជាមិនខាន ខ១៦. ហេតុនោះបានជាត្រូវឲ្យពួកកូនចៅអ៊ីស្រាអែលបានស្មោះត្រង់ដល់ថ្ងៃឈប់សំរាកនោះ ដើម្បីនឹងកាន់តាមនៅអស់ទាំងដំណគេតរៀងទៅ ទុកជាសេចក្ដីសញ្ញានៅអស់កល្បជានិច្ច ខ១៧. នោះហើយជាទីសំគាល់ដល់អញ ហើយនឹងពួក

កូនចៅអ៊ីស្រាអែល ជាដរាបរៀងរាបតទៅ ដ្បិតព្រះយេហូវ៉ា ទ្រង់បាន បង្កើតផ្ទៃមេឃ នឹងផែនដីក្នុងរវាង៦ថ្ងៃ លុះដល់ថ្ងៃទី៧ នោះទ្រង់ក៏ ឈប់សំរាក ហើយបានលំហើយព្រះអង្គវិញ» (៣១២-១៧) បន្ទាប់ពី ប្រែចិត្តពីអំពើបាប ពួកជំនុំកាឡាទី មិនមានបញ្ហាក្នុងការរក្សាថ្ងៃឈប់ សំរាក ឬថ្ងៃសប្ប័ទ នឹងថ្ងៃបុណ្យបរិសុទ្ធ ទាំងប៉ុន្មានរបស់ព្រះនោះទៀត ទេ ពីព្រោះវិញ្ញាណបរិសុទ្ធរបស់ព្រះ បាននាំពួកគេចូលទៅក្នុងគ្រប់ អស់ទាំងសេចក្ដីពិត។ សាវកប៉ុលសរសេរថា ៦. «ហើយដោយព្រោះ អ្នករាល់គ្នាជាកូន បានជាព្រះទ្រង់ចាត់វិញ្ញាណបរិសុទ្ធនៃព្រះរាជបុត្រា នៃទ្រង់ឲ្យមកក្នុងចិត្តអ្នករាល់គ្នា ឲ្យបន្លឺឡើងថា អ័ប្បា ព្រះវរបិតាអើយ ៧. ដូច្នេះ អ្នករាល់គ្នាមិនមែនជាអ្នកបំរើទៀតទេ គឺជាកូនវិញ ហើយ បើជាកូន នោះនឹងបានមរដកនៃព្រះ ដោយសារព្រះគ្រីស្ទដែរ» (កាឡាទី៤:៦-៧) រួចក្រោយមកទៀត សាវកប៉ុលបានរំលឹកគេ អំពីព្រះ ក្លែងក្លាយ ដែលពួកគេធ្លាប់មាន ជាព្រះរបស់អារក្សសាតាំង ដែលវា បានតាំងឡើង សំរាប់នាំមនុស្សឲ្យវង្វេង។ ចូរកត់ចំណាំការប្រៀបធៀប: ៨ «នៅវេលានោះ...[មកដល់ថ្ងៃប្រែចិត្ត]...កាលអ្នកមិនទាន់ស្គាល់ព្រះ ...[មិនស្គាល់ថ្ងៃសប្ប័ទ នឹងថ្ងៃបុណ្យបរិសុទ្ធ]... នោះត្រូវជាប់បំរើដល់ របស់ទាំងអស់ ដែលមិនមែនជាព្រះពីកំណើតទេ... [ព្រះក្លែងក្លាយ នឹង អារក្សសាតាំង] ដូច្នេះ ការថ្វាយបង្គំព្រះក្លែងក្លាយ គ្មានទាក់ទងអ្វី នឹង ការថ្វាយបង្គំព្រះពិត នៅថ្ងៃសប្ប័ទ នឹងថ្ងៃបុណ្យបរិសុទ្ធទាំងប៉ុន្មាន របស់ព្រះនោះទេ។ បន្ទាប់ពីពួកគេបានប្រែចិត្តចេញ ពីការថ្វាយបង្គំព្រះ

ក្លែងក្លាយ លោកសាវកប៉ុលបានបង្រៀនពួកគេ ពីផ្លូវរបស់ព្រះ ជាផ្លូវនៃជីវិត ឲ្យពួកគេរក្សាថ្ងៃសប្ប័ទជាបរិសុទ្ធ នឹងប្រារព្ធធ្វើបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះ ដូចដែលលោកបានបង្រៀនដល់គ្រប់អស់ទាំងពួកជំនុំជំនុំនៃព្រះអម្ចាស់ នោះគ្រប់ទីកន្លែងៗ សាវកប៉ុលបានដាស់តឿននឹងប្រមានយ៉ាងម៉ឺនម៉ាត់ដល់ពួកជំនុំកាឡាទី ថាគេកំពុងតែប្រឈមមុខនឹងគ្រោះថ្នាក់ខាងវិញ្ញាណយ៉ាងធ្ងន់ធ្ងរ ពីព្រោះពួកគេមិនស្តាប់បង្គាប់តាមព្រះ ដោយបានត្រឡប់ទៅឯព្រះក្លែងក្លាយវិញ ទាំងបង្កើតឲ្យមានការច្របូកច្របល់នៅក្នុងពួកជំនុំ ដោយបានបែរខ្នងដាក់ព្រះដ៏ជាព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដោយហេតុនោះហើយ បានជាសាវកប៉ុលស្តីបន្ទោសយ៉ាងខ្លាំងដល់ពួកគេ ៤៩. «តែឥឡូវនេះ លុះបានស្គាល់ព្រះហើយ (តែស៊ូថា ព្រះបានស្គាល់អ្នករាល់គ្នាវិញជាជាង) នោះធ្វើដូចម្តេចឲ្យអ្នករាល់គ្នាបានត្រឡប់ទៅឯបឋមសិក្សាខ្សោយ ហើយទាបថោក... [ដែលអ្នករាល់គ្នាចង់ទៅតាមវិញ្ញាណរបស់អារក្សសាតាំងនៃពួកសាសនាក្លែងក្លាយ ដូចកាលពីមុនប្រែចិត្ត]... ដែលអ្នករាល់គ្នាចង់ទៅជាប់បំរើម្តងទៀតនោះ... [បំរើអារក្សសាតាំង ដូចពីមុនទៀត] ... ៤១០ អ្នករាល់គ្នាជាអ្នកកាន់ថ្ងៃ ខែ រដូវ នឹងឆ្នាំផ្សេងៗ...[របស់ព្រះក្លែក្លាយ] ... ៤១១. ខ្ញុំខ្លាចក្រែងខ្ញុំបានធ្វើការនឿយហត់ ក្នុងពួកអ្នករាល់គ្នាជាឥតប្រយោជន៍» (កាឡាទី៤:៨-១១) សូមបញ្ជាក់ ម្តងទៀត ពីមុនការប្រែចិត្តពីអំពើបាបពួកជំនុំកាឡាទីមិនស្គាល់ព្រះពិត មិនស្គាល់ថ្ងៃសប្ប័ទ ឬច្បាប់ នឹង ក្រិត្យ

វិន័យរបស់ព្រះទេ ដូច្នេះ មិនអាចយកន័យថា ថ្ងៃ ខែ រដូវ នឹងឆ្នាំ ជាថ្ងៃសប្ប័ទ នឹងថ្ងៃបុណ្យបរិសុទ្ធរបស់ព្រះអម្ចាស់នោះបានទេ។ ពាក្យថា «ថ្ងៃ ខែ រដូវ នឹងឆ្នាំ» ដែលគម្ពីរកាឡាទីបានចែងនោះ គឺជា ថ្ងៃ ខែ រដូវ នឹងឆ្នាំ របស់ព្រះក្លែងក្លាយ ដែលពួកកាឡាទីធ្លាប់បំរើ ពីមុនមានការប្រែចិត្ត ប៉ុណ្ណោះ។ ឯពួកជំនុំកាឡាទី គេបានបំភ្លេចចោលការថ្វាយបង្គំព្រះ នៅថ្ងៃអាទិត្យ ឬថ្វាយបង្គំព្រះក្លែងក្លាយ តាមថ្ងៃ ខែ រដូវ នឹងឆ្នាំ ដែលពួកបំរើព្រះក្លែងក្លាយទាំងអស់នោះ គេបានរៀបចំឡើង។ ពួកជំនុំកាឡាទី បានប្រែចិត្ត ពីការទាំងអស់នោះ មកថ្វាយបង្គំព្រះនៅសប្ប័ទ ជាថ្ងៃទី៧ ហើយបានប្រារព្ធធ្វើបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះផង មិនដូចពួកសាសនៈវិទូរបស់ពួកជំនុំអ័ចូដក ប្រកាសនោះទេ។ តាមការពិត មានការកើតឡើងផ្ទុយពីសេចក្ដីប្រកាសនោះវិញទេ! កំណត់ចំណាំៈ ដោយយកចិត្តទុកដាក់ អំពីសំបុត្ររបស់សាវកប៉ុល ដែលលោកប្រើពាក្យ "សប្ប័ទ" ឬ "ថ្ងៃបរិសុទ្ធ" ក្នុងការសរសេរ ទៅពួកជំនុំកាឡាទី ដែលបានត្រឡប់ទៅឯផ្លូវចាស់របស់គេវិញ ដោយទៅគោរព ថ្ងៃ ខែ រដូវ នឹងឆ្នាំ របស់ព្រះក្លែងក្លាយ ដែលពួកគេធ្លាប់បានគោរពពីមុន។ ប្រសិនបើ សាវកប៉ុល សរសេរទៅពួកគេ អំពីថ្ងៃសប្ប័ទ ឬថ្ងៃបុណ្យបរិសុទ្ធរបស់ព្រះ នោះសាវកប៉ុល លោកពិត ជាប្រើពាក្យ ថ្ងៃបរិសុទ្ធ នឹងថ្ងៃបុណ្យបរិសុទ្ធរបស់ព្រះជាមិនខាន។ សាវកប៉ុលពិតជាមិនប្រើពាក្យ "ថ្ងៃ ខែ រដូវ នឹងឆ្នាំ"

នោះទេ ដូច្នេះ ថ្ងៃ ខែ រដូវ នឹងឆ្នាំ ពិតជារបស់ព្រះក្លែងក្លាយ ដែលពួកគ្រីស្ទានអ័ថូដក មិនបានស្មោះត្រង់ ក្នុងការបកប្រែ គេបកប្រែលំអៀងព្រះបន្ទូលរបស់ព្រះ ប្រឆាំងថ្ងៃសប្ប័ទ នឹង ថ្ងៃបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះអម្ចាស់។ ពួកគ្រីស្ទានអ័ថូដក បដិសេធបញ្ញត្តិបរិសុទ្ធរបស់ព្រះ ដើម្បីឲ្យគេអាចថ្វាយបង្គំព្រះនៅថ្ងៃអាទិត្យ នឹងធ្វើបុណ្យផ្សេងៗរបស់លោកីយនេះ។ គម្ពីររ៉ូម១៤:១-៦ ២១. «ចូរទទួលអ្នកណាដែលខ្សោយខាងឯសេចក្តីជំនឿដែរ មិនមែនឲ្យបានជជែកគ្នាពីសេចក្តីប្រកាន់ផ្សេងៗឡើយ ២២. ដ្បិតម្នាក់ជឿថា បរិភោគបានគ្រប់មុខទាំងអស់ ម្នាក់ទៀតដែលខ្សោយ បរិភោគតែបន្លែទេ ២៣. កុំឲ្យអ្នកដែលបរិភោគ មើលងាយដល់អ្នកដែលមិនបរិភោគឡើយ ក៏កុំឲ្យអ្នកដែលមិនបរិភោគនិន្ទាអ្នកដែលបរិភោគដែរ ដ្បិតព្រះទ្រង់ ទទួលអ្នកនោះដូចគ្នា ២៤. តើអ្នកជាអ្វីដែលនិន្ទាបាវរបស់គេ អ្នកនោះឈរឬដួលក្តី នោះស្រេចនឹង ចៅហ្វាយទេតើ ហើយគេនឹងបានឈរមែន ដ្បិតព្រះទ្រង់អាចនឹងតាំងឲ្យឈរបាន ២៥. ម្នាក់រាប់ថា ថ្ងៃមួយល្អជាងថ្ងៃមួយ ម្នាក់ទៀតរាប់ថាថ្ងៃណាក៏ដូចជាថ្ងៃណា ត្រូវឲ្យគ្រប់គ្នាជឿពិតប្រាកដក្នុងខ្លួន ២៦. អ្នកណា ដែលប្រកាន់ថ្ងៃណា នោះក៏ប្រកាន់ដោយគោរពដល់ព្រះអម្ចាស់ ហើយអ្នកណាដែលមិនប្រកាន់ថ្ងៃណា នោះក៏មិនប្រកាន់ ដោយគោរពដល់ព្រះអម្ចាស់ដែរ អ្នកណាដែលបរិភោគ នោះបរិភោគ ដោយគោរពដល់ព្រះអម្ចាស់ ដ្បិតគេអរព្រះគុណដល់ព្រះ ហើយអ្នកណាដែលមិន

បរិភោគនោះ គឺមិនបរិភោគដោយគោរពដល់ព្រះអម្ចាស់ដែរ ក៏អរព្រះគុណដល់ព្រះដូចគ្នា» (៦១-៦) សេចក្តីបញ្ជាក់ ១៥. «ម្នាក់រាប់ថាថ្ងៃមួយល្អជាងថ្ងៃមួយ» ចូរយល់គន្លឹះពាក្យ នៅ១៥. នឹង ១៦. ជាទូទៅពួកអ័ថូដក នឹងពួកគ្រីស្ទបរិស័ទ របស់លោកីយនេះ គេបកប្រែទៅតាមបំណងចិត្តរបស់ពួកគេ ដើម្បីឲ្យអាចថ្វាយបង្គំព្រះនៅថ្ងៃអាទិត្យ «ថ្ងៃណាក៏ដូចជាថ្ងៃណា ត្រូវឲ្យគ្រប់គ្នាជឿពិតប្រាកដក្នុងចិត្ត» មានការសោកស្តាយយ៉ាងខ្លាំង ពីការបកប្រែបទគម្ពីរនេះ ផ្ទុយពីសេចក្តីពិត។ ព្រះអម្ចាស់ទ្រង់បានបង្កើតផ្ទៃមេឃ នឹងផែនដី ព្រមទាំងរបស់សព្វសារពើ នៅស្ថានទាំងនោះ នឹងបង្កើតឪពុក ម្តាយដើមរបស់មនុស្ស។ លោកុប្បត្តិ២:២-៣ «លុះដល់ថ្ងៃទី៧...(សព្វថ្ងៃ គឺថ្ងៃសៅរ៍)...ការដែលព្រះទ្រង់ធ្វើ នោះបានហើយជាស្រេច ទ្រង់ក៏ឈប់ផ្អាកសំរាកនៅថ្ងៃទី៧នោះ ពីគ្រប់ទាំងការដែលទ្រង់ធ្វើ ព្រះទ្រង់ក៏ប្រទានពរដល់ថ្ងៃទី៧នោះ ព្រមទាំងញែកទុកជាថ្ងៃបរិសុទ្ធ ពីព្រោះនៅថ្ងៃនោះ ទ្រង់បានឈប់សំរាក... (ថ្ងៃសប្ប័ទ)...ពីគ្រប់ទាំងការដែលទ្រង់បានបង្កើតបានធ្វើ» ព្រះអម្ចាស់ទ្រង់រៀបចំផែនការ នៃសេចក្តីសង្គ្រោះសំរាប់មនុស្សទ្រង់បានរៀបចំថ្ងៃសប្ប័ទ ជាថ្ងៃបរិសុទ្ធ សំរាប់ថ្វាយបង្គំព្រះអង្គ ព្រះទ្រង់ក៏បានរៀបចំ ថ្ងៃបុណ្យបរិសុទ្ធ ទាំងប៉ុន្មានរបស់ព្រះអង្គសំរាប់មនុស្សដែរ (លេវីវិន័យ២៣:១-៤៤) «អ្នកណាដែលប្រកាន់ថ្ងៃណានោះក៏ប្រកាន់ដោយគោរពដល់ព្រះអម្ចាស់ ហើយអ្នកដែលមិនប្រ

កាន់ថ្ងៃណា នោះក៏មិនប្រកាន់ ដោយគោរពដល់ព្រះអម្ចាស់ដែរ អ្នកណាដែលបរិភោគ នោះបរិភោគដោយគោរពដល់ព្រះអម្ចាស់ ដ្បិតគេអរព្រះគុណដល់ព្រះ ហើយអ្នកណាដែលមិនបរិភោគ នោះគឺមិនបរិភោគ ដោយគោរពដល់ព្រះអម្ចាស់ដែរ ក៏អរព្រះគុណដល់ព្រះដូចគ្នា» (រ៉ូម១៤:៦) លោកសាវកប៉ុលបានបញ្ជាក់ថែមទៀត ពីបញ្ហាការបរិភោគសាច់ នឹងការបរិភោគបន្លែ លោកបានពន្យល់ថា រ៉ូម១៤ ខ១៥. «ប៉ុន្តែ បើអ្នកធ្វើឲ្យបងប្អូនអ្នកព្រួយចិត្ត ដោយព្រោះម្ហូបចំណីអ្វី នោះអ្នកប្រព្រឹត្តមិនមែនដោយស្រឡាញ់ទៀតទេ កុំធ្វើឲ្យអ្នកណាដែលព្រះគ្រីស្ទបានសុគតជំនួស ត្រូវវិនាសដោយសារម្ហូបរបស់អ្នកឡើយ ខ១៦. ក៏កុំឲ្យគេមានឱកាសនឹងនិយាយអាក្រក់ ពីអ្នករាល់គ្នាដែរ ខ១៧. ដ្បិតនគរព្រះមិនសំរេចនឹងការស៊ី ឬផឹកនោះទេ គឺស្រេចនឹងសេចក្ដីសុចរិត សេចក្ដីមេត្រី នឹងសេចក្ដីអំណរ ដោយនូវវិញ្ញាណបរិសុទ្ធរបស់ព្រះវិញទេតើ ខ១៨. ពីព្រោះអ្នកណាដែលបំរើព្រះគ្រីស្ទដោយសារសេចក្ដីទាំងនោះ អ្នកនោះជាទីគាប់ព្រះហឫទ័យដល់ព្រះហើយ ព្រមទាំងមានមនុស្សរាប់អានដល់ខ្លួនដែរ... ខ២០. កុំឲ្យបំផ្លាញការព្រះ ដោយព្រោះតែម្ហូបណានោះឡើយ គ្រប់របស់ទាំងអស់ឈ្មោះថាស្អាតមែន តែរមែងជាអាក្រក់ដល់អ្នកណាដែលបរិភោគដោយប្រទាំងវិញ ខ២១. គួរតែកុំបរិភោគសាច់ ឬស្រាទំពាំងបាយជូរ ឬអ្វីដែលនាំឲ្យបងប្អូនអ្នកជំពប់ ឬរវាតចិត្ត ឬធ្វើឲ្យខ្សោយនោះឡើយ

២២. អ្នកឯងមានសេចក្តីជំនឿយ៉ាងណា ចូរជឿយ៉ាងនោះតែម្នាក់ឯង នៅចំពោះព្រះចុះ មានពរហើយ អ្នកណាដែលមិនកាត់ទោសខ្លួនឯង ក្នុងការដែលខ្លួនរាប់ថាធ្វើបាន» (១៥-១៨, ២០-២២) សាវកប៉ុលមិនបានផ្តល់សិទ្ធិឲ្យពួកជំនុំសាសន៍ដទៃ ជ្រើសរើសយកថ្ងៃណាមួយក្នុងសប្តាហ៍ ជាថ្ងៃបរិសុទ្ធ សំរាប់ថ្វាយបង្គំព្រះនោះទេ។ ការថ្វាយបង្គំព្រះអម្ចាស់ គឺទ្រង់បានរៀបចំរួចស្រេចហើយ ទុកសំរាប់មនុស្សដែលព្រះអម្ចាស់ទ្រង់ បានបង្កើតគេមក លោកុប្បត្តិ២:១-៣ ១.«ដូច្នេះផ្ទៃមេឃនឹងផែនដីក៏បានរួចជាស្រេច ព្រមទាំងរបស់សព្វសារពើផង ២. លុះដល់ថ្ងៃទី៧ ការដែលព្រះទ្រង់ធ្វើ នោះបានហើយជាស្រេច ទ្រង់ក៏ឈប់ផ្អាកសំរាកនៅថ្ងៃទី៧នោះ ពីគ្រប់ទាំងការដែលទ្រង់ធ្វើ ៣. ព្រះទ្រង់ក៏ប្រទានពរដល់ថ្ងៃទី៧នោះ ព្រមទាំងញែកទុកជាថ្ងៃបរិសុទ្ធ ពីព្រោះនៅថ្ងៃនោះ ទ្រង់បានឈប់សំរាក ពីគ្រប់ទាំងការដែលទ្រង់បានបង្កើតបានធ្វើ» (១-៣) ដូច្នេះ ការថ្វាយបង្គំព្រះ នោះស្រេចនៅលើព្រះដែលទ្រង់បានរៀបចំទុកជាស្រេច មិនមែនជាមនុស្សទេ ដែលរៀបចំថ្ងៃសំរាប់ថ្វាយបង្គំព្រះនោះទេ។ គម្ពីររ៉ូមជំពូក១៤ សាវកប៉ុលមិនបានបង្រៀនពីការថ្វាយបង្គំព្រះនៅថ្ងៃអាទិត្យ ឬថ្ងៃណាមួយក្នុងសប្តាហ៍ ដើម្បីថ្វាយបង្គំព្រះនោះទេ។ នៅក្នុងព្រះគម្ពីរបរិសុទ្ធ ព្រះអម្ចាស់បានបង្គាប់យ៉ាងច្បាស់ពីថ្ងៃដែលត្រូវថ្វាយបង្គំទ្រង់ គឺនៅថ្ងៃឈប់សំរាក ជាថ្ងៃទី៧ ឬថ្ងៃសប្ប័ទ «ចូរឲ្យ

ទឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ ក្នុងរវាង៦ថ្ងៃ នោះត្រូវឲ្យឯងធ្វើអស់ទាំងការរបស់ឯងចុះ តែឯថ្ងៃទី៧ នោះគឺជាថ្ងៃឈប់សំរាកថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ នៅថ្ងៃនោះមិនត្រូវធ្វើអ្វីឲ្យសោះ ទោះខ្លួនឯងឬកូនប្រុសកូនស្រីឯងក្តី ទោះបាវប្រុស ឬបាវស្រីឯងក្តី ទោះសត្វរបស់ឯង ឬអ្នកដទៃដែលនៅផ្ទះឯងក្តី ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ាទ្រង់បានធ្វើផ្ទៃមេឃ ផែនដី ហើយនឹងសមុទ្រ ព្រមទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ រួចដល់ថ្ងៃទី៧ ទ្រង់ឈប់សំរាក ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់ថ្ងៃឈប់សំរាក ហើយក៏ញែកចេញជាបរិសុទ្ធ» (និក្ខមនំ ២០:៨-១១)

**តើព្រះយេស៊ូវគ្រីស្ទបានលុបចោលថ្ងៃឈប់សំរាក ជាថ្ងៃទី៧ឬ?**

សេចក្តីបង្រៀនប្រៀបធៀបរបស់ព្រះយេស៊ូវគ្រីស្ទ ផ្ទុយស្រឡះពីគំនិតពួកអ្នកមានប្រជាប្រិយភាពមួយចំនួន នឹងសេចក្តីបង្រៀនរបស់ពួកគេ ឲ្យបោះបង់ចោលបញ្ញត្តិទី៤។ ព្រះបន្ទូលនៅលើភ្នំ ព្រះយេស៊ូវបានបញ្ជាក់យ៉ាងច្បាស់ថា «ដូច្នេះ អ្នកណាដែលនឹងរំលងបទណាមួយ សូម្បីយ៉ាងតូចបំផុត ក្នុងបញ្ញត្តិទាំងនេះ ហើយបង្រៀនមនុស្សឲ្យធ្វើដូច្នោះដែរ នោះនឹងត្រូវហៅជាអ្នកតូចបំផុតក្នុងនគរស្ថានសួគ៌ តែអ្នកណាដែលកាន់តាម ហើយបង្រៀនចំពោះបញ្ញត្តិទាំងនេះ នោះនឹងបានហៅជាអ្នកធំក្នុងនគរស្ថានសួគ៌វិញ» (ម៉ាថាយ៥:១៩) តើបញ្ញត្តិមួយណារបស់ព្រះ ដែលត្រូវគ្រីស្តាន (គ្រីស្ទាន) ឬគ្រីស្តបរិស័ទបដិសេធ នឹងត្រូវបានចាត់ទុក «យ៉ាង

តូចបំផុត?» គឺជាបញ្ញត្តិទី៤ ដែលគ្រីស្តបរិស័ទរាប់ពាន់លាននាក់បាន បដិសេធ ហើយបានប្រកាសឲ្យរក្សាថ្ងៃអាទិត្យ ជាថ្ងៃត្រូវថ្វាយបង្គំព្រះវិញ ហើយគេអួតអាងថា គេកំពុងតែធ្វើតាមព្រះហឫទ័យរបស់ព្រះៗ លោក យ៉ាកុប បានសរសេរថា «ដ្បិតអ្នកណាដែលកាន់ក្រិត្យវិន័យទាំងមូល តែ ភ្លាត់ជំពប់នឹងបទណាមួយ នោះក៏ត្រឡប់ជាមានទោសចំពោះក្រិត្យវិន័យ ទាំងមូលនោះហើយ» (យ៉ាកុប២:១០) ចូរយើងពិនិត្យមើលឡើងវិញ ពី បទបញ្ញត្តិទី៤ សារជាថ្មី ដែលពួកគ្រីស្តបរិស័ទរបស់លោកីយនេះ គេ បដិសេធៗ ព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់មានបន្ទូលថា «ចូរឲ្យនឹកចាំពី ថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ ក្នុងរវាង៦ថ្ងៃ នោះ ត្រូវឲ្យឯងធ្វើអស់ទាំងការរបស់ឯងចុះ តែឯថ្ងៃទី៧ នោះគឺជាថ្ងៃឈប់សំ រាកថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ នៅថ្ងៃនោះមិនត្រូវធ្វើអ្វីឲ្យសោះ ទោះខ្លួនឯងឬកូនប្រុសកូនស្រីឯងក្តី ទោះបាវប្រុស ឬបាវស្រីឯងក្តី ទោះ សត្វរបស់ឯង ឬអ្នកដទៃ ដែលនៅផ្ទះឯងក្តី ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ា ទ្រង់បានធ្វើផ្ទៃមេឃ ផែនដី ហើយនឹងសមុទ្រ ព្រមទាំងរបស់សព្វសារ ពើនៅស្ថានទាំងនោះដែរ រួចដល់ថ្ងៃទី៧ ទ្រង់ឈប់សំរាក ហេតុនោះ បានជាព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់ថ្ងៃឈប់សំរាក ហើយក៏ ញែកចេញជាបរិសុទ្ធ» (និក្ខមនំ២០:៨-១១) គ្មានកន្លែងណាមួយ នៅ ក្នុងព្រះគម្ពីរទាំងមូល ពីគម្ពីរលោកុប្បត្តិ ទៅដល់គម្ពីរវិវរណៈ រកមិន ឃើញមានខគម្ពីរណា ដែលផ្លាស់ប្តូរពីថ្ងៃទី៧ ជាថ្ងៃដែលព្រះអម្ចាស់

បានរៀបចំសំរាប់មនុស្សដែលទ្រង់បង្កើត ឲ្យបានសំរាក ដើម្បីថ្វាយបង្គំទ្រង់ ទៅថ្ងៃទី១ ឬថ្ងៃអាទិត្យនោះ គ្មានទេ។ ពួកអ្នកថ្វាយបង្គំព្រះថ្ងៃអាទិត្យ បកប្រែបទគម្ពីរជាច្រើន ដើម្បីគាំទ្រការថ្វាយបង្គំព្រះនៅថ្ងៃអាទិត្យរបស់ពួកគេ។ ព្រះយេស៊ូវគ្រីស្ទទ្រង់ជាម្ចាស់នៃថ្ងៃឈប់សំរាក ឬជាម្ចាស់នៃថ្ងៃទី៧ ទ្រង់មិនបានផ្លាស់ប្តូរថ្ងៃទី៧ ជាថ្ងៃថ្វាយបង្គំព្រះ ឲ្យទៅថ្ងៃអាទិត្យនោះទេ។ ព្រះយេស៊ូវគ្រីស្ទទ្រង់មានបន្ទូលថា «...ថ្ងៃឈប់សំរាកបានតាំងសំរាប់ឲ្យមនុស្ស មិនមែនជាមនុស្សសំរាប់ថ្ងៃឈប់សំរាកទេ ដូច្នេះ កូនមនុស្សជាម្ចាស់នៃថ្ងៃឈប់សំរាកដែរ» (ម៉ាកុស២:២៧-២៨) ចូរចងចាំព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់មានបន្ទូល «កុំឲ្យគិតស្មានថា ខ្ញុំមកដើម្បីនឹងលើកក្រិត្យវិន័យ ឬទំនាយពួកហោរាចោលឡើយ ខ្ញុំមិនមែនមកនឹងលើកចោលទេ គឺមកនឹងធ្វើឲ្យសំរេចវិញ ...[គឺដំកើងក្រិត្យវិន័យខាងសាច់ឈាម ឲ្យទៅជាក្រិត្យវិន័យខាងវិញ្ញាណនឹងជីវិតវិញ]...ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា នឹងគ្មានបាំងឈើ១ ឬក្បៀស១នៅក្នុងក្រិត្យវិន័យ ត្រូវបាត់ឡើយ ដរាបដល់កាលណាមេឃនឹងផែនដី បានកន្លងបាត់ទៅ គឺទាល់តែសេចក្តីទាំងអស់បានសំរេចដោយសព្វគ្រប់» (ម៉ាថាយ៥:១៧-១៨) ព្រះអម្ចាស់ទ្រង់បាន បង្កើត ថ្ងៃ ខែ រដូវ នឹងឆ្នាំ ទុកជាទីសំគាល់ សំរាប់មនុស្សប្រើប្រាស់ហើយ ទ្រង់ក៏បង្កើតថ្ងៃឈប់សំរាក ជាថ្ងៃទី៧ ឬថ្ងៃសប្ប័ទ សំរាប់មនុស្សដែរ។ ព្រះអម្ចាស់ទ្រង់ក៏បានបង្កើត ថ្ងៃទី៧ ទុកជាថ្ងៃឈប់ មិនមែនជា

មនុស្សដែលបង្កើត ថ្ងៃឈប់សំរាកទេ គឺជាព្រះវិញ។ ព្រះយេស៊ូវគ្រីស្ទ ទ្រង់មានបន្ទូលថា «ដ្បិតកូនមនុស្ស...[ព្រះយេស៊ូវ]... ជាម្ចាស់លើថ្ងៃឈប់សំរាកដែរ» (ម៉ាថាយ១២:៨) ថ្ងៃទី៧ ឬថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ ជាថ្ងៃបរិសុទ្ធ ដែលមានវត្តមាននៃព្រះអម្ចាស់នៅថ្ងៃទី៧ ជាថ្ងៃបរិសុទ្ធ ព្រះគម្ពីរបានចែងយ៉ាងច្បាស់ពីបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះ គឺជាថ្ងៃបរិសុទ្ធ គឺយើងរាល់គ្នាត្រូវតែកាន់ខ្ជាប់ ព្រមទាំងរក្សាថ្ងៃសប្ប័ទឲ្យបានបរិសុទ្ធផង។

**ថ្ងៃបុណ្យបរិសុទ្ធ ទាំងប៉ុន្មានរបស់ព្រះ**

- គម្ពីរលេវីវិន័យ២៣:៤-៥ (១) បុណ្យរំលង
- លេវីវិន័យ២៣:៦-៨ (២) បុណ្យនំបុ័ងឥតដំបែ ៧ថ្ងៃ
- លេវីវិន័យ២៣:១៥-១៦ (៣) បុណ្យថ្ងៃទី៥០
- លេវីវិន័យ២៣:២៣-២៥ (៤) បុណ្យផ្លុំត្រែ
- លេវីវិន័យ២៣:២៦-៣២ (៥) ថ្ងៃឲ្យធួននឹងបាប (តមអត់)
- លេវីវិន័យ២៣:៣៣-៣៧ (៦) បុណ្យបារាំ ៧ថ្ងៃ
- លេវីវិន័យ២៣:៣៦-៤២ (៧) (ថ្ងៃដ៏ធំអស្ចារ្យ)

ថ្ងៃបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះខាងលើនេះ យើងត្រូវតែប្រារព្ធធ្វើឲ្យបានខ្ជាប់ខ្ជួនជាទីបំផុត ពីព្រោះជាបុណ្យបរិសុទ្ធរបស់ព្រះនៃយើងរាល់គ្នា។

## សេចក្តីពន្យល់ ពីបុណ្យបរិសុទ្ធរបស់ព្រះ

១. បុណ្យរំលង

សញ្ញាចាស់: ព្រះតាំងសេចក្តីសន្យានឹងអ័ប្រាហាំថា ព្រះអង្គទ្រង់នឹងរក្សាទុកកូនច្បង ហើយជំនុំជំរះព្រះស្រុកអេស៊ីព្ទ (លោកុប្បត្តិ១៥:១៨, និក្ខមនំ១១:៤-៧)

សញ្ញាថ្មី: ព្រះទ្រង់សំដែងសេចក្តីស្រឡាញ់ ដោយប្រទានព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាតែមួយ ឲ្យមកសុគតសំរាប់លោះបាបរបស់មនុស្សក្នុងលោកីយ យើងបានសង្គ្រោះរួចពីបាប ដោយព្រះលោហិត នឹងសេចក្តីសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីតាំងសញ្ញាថ្មីតាមរយៈរូបអង្គទ្រង់ នឹងព្រះលោហិតទ្រង់ សំរាប់ជីវិតអស់កល្ប (២កូរិនថូស៥:២១, យ៉ូហាន១០:២៨)

២. បុណ្យនំបុ័ងឥតដំបែ (៧ថ្ងៃ)

សញ្ញាចាស់: ព្រះទ្រង់បានតាំងសេចក្តីសញ្ញានឹងអ័ប្រាហាំថា ទ្រង់នឹងការពារកូនច្បងរបស់សាសន៍អ៊ីស្រាអែល ហើយជំនុំជំរះព្រះនៃស្រុកអេស៊ីព្ទ នឹងនាំកូនចៅសាសន៍អ៊ីស្រាអែល ចេញពីស្រុកអេស៊ីព្ទមកទឹកដីសន្យាវិញ (និក្ខមនំ១១:៤-៧, លោកុប្បត្តិ១៥:១៣-១៦)

សញ្ញាថ្មី: គ្រីស្ទានឥតដំបែក្នុងព្រះគ្រីស្ទ មានជ័យជំនះលើអំពើបាបដោយអំណាចវិញ្ញាណបរិសុទ្ធរបស់ព្រះ ហើយដើរក្នុងជីវិតបែប

ថ្មី ដោយកាន់តាមបញ្ញត្តិបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះ យើងជាពូជលោកអ័ប្រាហាំ ដោយវិញ្ញាណ (១កូរិនថូស៥:៧-៨, កាឡាទី៣:២៩)

៣. ថ្ងៃទី៥០

សញ្ញាចាស់: សាសន៍អ៊ីស្រាអែលទទួលបញ្ញត្តិនៅភ្នំស៊ីណាយ ផលដំបូង ពីស្រូវសាលី នឹងស្រូវឪក (លេវីវិន័យ២៣:៩-១១, ហោទិយកថា៨:៧-៨)

សញ្ញាថ្មី: ពួកជំនុំទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះ គ្រីស្ទានជាផលដំបូងថ្វាយព្រះ ពេលទ្រង់ប្រោសឲ្យយើងរស់ពីស្លាប់ឡើងវិញ (រ៉ូម១៦:៥, ១កូរិនថូស១៥:៥១-៥២)

៤. បុណ្យផ្លុំត្រែ

សញ្ញាចាស់: ផ្លុំត្រែរំលឹក ព្រះទ្រង់មានវត្តមាននៅឯព្រះវិហារ (១របាក្សត្រ១៥:១៦-២៤)

សញ្ញាថ្មី: ព្រះទ្រង់មានជ័យជំនះលើអារក្សសាតាំង នឹងលើអស់ទាំងបីសាច ព្រះគ្រីស្ទ នឹងពួកបរិសុទ្ធ ចុះពីសមុទ្រកែវ មកផែនដីវិញ (១ថែស្សាឡូនីច៤:១៤-១៧, វិវរណៈ១៥:២-៤, ១៩:១៤)

៥. ឲ្យធួននឹងបាប (តមអត់)

សញ្ញាចាស់: ពួកសង្ឃថ្វាយដង្វាយដល់ព្រះយេហូវ៉ា ឲ្យធួននឹងបាបរបស់ពួកអ៊ីស្រាអែល ហើយនឹងបញ្ឈឺចិត្តខ្លួន (លេវីវិន័យ២៣:២៦-៣២)

**សញ្ញាថ្មី:** សាតាំងត្រូវចាប់ចងបោះក្នុងជង្ហុកជំ១ពាន់ឆ្នាំ ព្រះយេស៊ូវគ្រីស្ទថ្វាយអង្គទ្រង់ជាយញ្ញបូជា លោះបាបមនុស្សទាំងអស់ ពួកបរិសុទ្ធជាវិញ្ញាណនឹងនៅជាមួយព្រះដ៏ជាព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទ (វិវរណៈ:២១:១-៤, វិវរណៈ:៥:១០)

**៦. បុណ្យបារាំ (៧ថ្ងៃ)**

**សញ្ញាចាស់:** ជាសេចក្តីរំលឹកពីពួកកូនចៅសាសន៍អ៊ីស្រាអែល នៅទីរហោស្ថាន (និក្ខមនំ, លេវីវិន័យ, ជនគណនា, ចោទិយកថា)

**សញ្ញាថ្មី:** ព្រះយេស៊ូវគ្រីស្ទយកនិស្ស័យជាសាច់ឈាម គង់ជាមួយមនុស្សព្រះយេស៊ូវគង់ជាមួយពួកបរិសុទ្ធដោយវិញ្ញាណ សាច់ឈាមនេះជាបណ្តោះអាសន្ន ពួកបរិសុទ្ធសោយរាជ្យ១ពាន់ឆ្នាំជាមួយព្រះគ្រីស្ទនៅផែនដី (ម៉ាថាយ១:១៨-២៥ យ៉ូហាន១៤:២៣, ១កូរិនថូស១៥:៤២-៥៨, វិវរណៈ:៥:១០, ២០:៤)

**៧. ថ្ងៃដ៏ធំអស្ចារ្យចុងក្រោយ**

**សញ្ញាចាស់:** ព្រះទ្រង់ប្រទានពរជាបរិបូរដល់ពួកកូនចៅអ៊ីស្រាអែល (១ពង្សាវតាក្សត្រ១០:២៣-២៨)

**សញ្ញាថ្មី:** ១) សេចក្តីរស់ពីស្លាប់ឡើងវិញលើកទី២ (វិវរណៈ:២០:៥-៦)

- ដំណាក់កាលទី១ មានឱកាសទទួលសេចក្តីសង្គ្រោះ (វិវរណៈ:២០:១១-១៤)
- ដំណាក់កាលទី២ សេចក្តីជំនុំជំរះចុងក្រោយ ពួកទុច្ចរិតបោះទៅក្នុងបឹងភ្លើង

តើសាវកប៉ុលបង្រៀនពួកសាសន៍ដទៃមិនឲ្យរក្សាថ្ងៃសប្ប័ទ នឹងថ្ងៃបុណ្យរបស់ព្រះឬ?

២) ស្ថានសួគ៌ នឹងផែនដីថ្មី (វិវរណៈ២១:១)

៣) ក្រុងយេរូសាឡឹមថ្មី ចុះពីស្ថានសួគ៌ (វិវរណៈ២១:២)

៤) ព្រះទ្រង់ចាប់ផ្តើមផែនការជីវិតអស់កល្ប (វិវរណៈ២២)

* * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * * *

គម្ពីរយោង:

១. កាឡាទី៤:៨-១០
២. រ៉ូម១៤:៦
៣. ហេព្រើរ៤:៩
៤. កិច្ចការ១៣:៤២-៤៤
៥. ១យ៉ូហាន៣:៤
៦. យ៉ូហាន៥:១៤
៧. យ៉ូហាន៨:១១
៨. រ៉ូម៣:៣១
៩. ហេព្រើរ១០:១៦
១០. រ៉ូម២:២៥-២៨
១១. រ៉ូម៦:១២
១២. កាឡាទី១:៦-១២
១៣. កាឡាទី២:១១-១៥
១៤. កាឡាទី៣៦:១០-១៣
២១. ១កូរិនថុស៧:១៧
២២. ១កូរិនថូស៥:៦-៨
២៣. ១កូរិនថូស១៤:៣៣
២៤. កិច្ចការ២៤:១៤
២៥. កាឡាទី៤:៦-១១
២៦. និក្ខមនំ៣១:១២-១៧
២៧. រ៉ូម១៤:១-៦
២៨. លកុប្បត្តិ២:១-៣
២៩. លេវីវិន័យ២៣:១-៤៤
៣០. រ៉ូម១៤:៦-២២
៣១. និក្ខមនំ២០:៨-១១
៣២. យ៉ាកុប២:១០
៣៣. ម៉ាកុស២:២៧-២៨
៣៤. ម៉ាថាយ៥:១៧-១៨

១៥. រ៉ូម៧:៧-១២

១៦. ហោទិយកថា២៨:១-១២

១៧. លេវីវិន័យ២៦:១-១៥

១៨. ហោទិកថា២៨:១៥-៦៨

១៩. លេវីវិន័យ២៦:១៦-៤៦

២០. យូដាស១:៤

៣៥. ម៉ាថាយ១២:៨

៣៦. រ៉ូម១៤:១៥,១៧-១៨

៣៧. រ៉ូម១៤:២០-២២

៣៨. ម៉ាថាយ៥:១៩

---

«គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញវិញ្ញាណបរិសុទ្ធទ្រង់បណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍ សំរាប់ការបង្រៀន ការរំលឹកឲ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងឯសេចក្តីសុចរិត ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះ សំរាប់នឹងធ្វើការល្អគ្រប់មុខ» (២ធីម៉ូថេ៣:១៦-១៧)

«ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្ត
ប្រយោជន៍កុំឲ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ»
(ទំនុកដំកើង១១៩:១១)

«ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ ក្នុងរវាង៦ថ្ងៃ នោះត្រូវឲ្យឯងធ្វើអស់ទាំងការរបស់ឯងចុះ តែឯថ្ងៃទី៧ នោះគឺជាថ្ងៃឈប់សំរាកថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ នៅថ្ងៃនោះ មិនត្រូវធ្វើអ្វីឲ្យសោះ ទោះខ្លួនឯងឬកូនប្រុសកូនកូនស្រីឯងក្តី ទោះបាវប្រុស ឬបាវស្រីឯងក្តី ទោះសត្វរបស់ឯង ឬអ្នកដទៃដែលនៅផ្ទះឯងក្តី ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ាទ្រង់បានធ្វើផ្ទៃមេឃ ផែនដី ហើយនឹងសមុទ្រ ព្រមទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ រួចដល់ថ្ងៃទី៧ ទ្រង់ឈប់សំរាក ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់ថ្ងៃឈប់សំរាក ហើយក៏ញែកចេញជាបរិសុទ្ធ» (និក្ខមនំ២០:៨-១១)

«...ថ្ងៃឈប់សំរាកបានតាំងសំរាប់ឲ្យមនុស្ស មិនមែនជាមនុស្សសំរាប់ថ្ងៃឈប់សំរាកទេ ដូច្នេះ កូនមនុស្ស...[ព្រះយេស៊ូវ]....ជាម្ចាស់នៃថ្ងៃឈប់សំរាកដែរ» (ម៉ាកុស២:២៧-២៨)